

# ត្រូវគ្នាវិញ

Let's Read
The Asia Foundation



ម៉ារី និង សាណា រស់នៅផ្ទះជិតគ្នា ហើយជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា។ ថ្ងៃមួយ សាណា បានយកកន្សែងចង្កេះដែលនាងចំណាយពេលធ្វើជាច្រើនថ្ងៃយកមកបង្ហាញ ម៉ារី។



សាណា ប្រាប់ដោយក្ដីរំភើបថា ”ខ្ញុំធ្វើកន្សែងនេះទុកជូនម្ដាយខ្ញុំ។ តើឯងយល់យ៉ាងណាដែរ?”

ម៉ារី ឆ្លើយតប ”ខ្ញុំគិតថា គាត់មិនពាក់វាទេ។ ខ្ញុំក៏មិនពាក់វាដែរ” ។

សាណា ក៏ងើបឡើង ហើយដើរចេញបាត់ទៅ។




ព្រឹកឡើង ម៉ារីឈរចាំសាណា។ ជារៀងរាល់ថ្ងៃ ពួកគេដើរទៅសាលាជាមួយគ្នា ។

ប៉ុន្តែព្រឹកនេះ សាណា ទៅចោលម៉ារី។



ម៉ារី បានយកសម្លការីត្រីទុកញ៉ាំពេលថ្ងៃត្រង់នៅសាលារៀន។ សាណា ចូលចិត្តញ៉ាំការីត្រី។ ប៉ុន្តែ សាណា បែរជាទៅញ៉ាំជាមួយរ៉ូលីនទៅវិញ។



ល្ងាចឡើង ម៉ារី ចាំ សាណា។ ម៉ារី ចង់លេងឡានដែលពួកគេ ទាំងពីរធ្លាប់ធ្វើជាមួយឪពុក ម៉ារី។ ប៉ុន្តែមិនឃើញ សាណា មក ទេ។ ម៉ារី បានសម្លឹងមើលរបស់របរទាំងអស់ដែលនាងបាន ធ្វើជាមួយសាណា នៅក្នុងទីធ្លាផ្ទះ មានខ្លុយ សម្បុកសត្វ និង ផ្លូវរទេះភ្លើង ជាដើម។



ម៉ារី ដកឡានដាក់ទៅម្ខាង។ នាងទាញឫស្សីវែងពីរដើម ដាក់ទន្ទឹមគ្នា។ នាងយកឫស្សីខ្លីមួយដើមដាក់បញ្ឆិតចន្លោះឫស្សីវែងទាំងពីរនោះ រួចយកខ្សែផ្តៅមកចង ដូចដែលនាងធ្លាប់ឃើញឪពុកនាងធ្វើ។ នាងចងឫស្សីខ្លីមួយទៀត បញ្ច្រាសជាមួយឫស្សីមុន។ បន្ទាប់មក នាងចងបន្តបឫស្សីខ្លីៗជាច្រើនទៀត។ បន្ទាប់មក នាងរលាស់ដៃ បោសធូលីដែលជាប់ដៃ ហើយសម្លឹងមើលអ្វីដែលនាងបានធ្វើ។ ម៉ារី គិត មិនដឹងធ្វើស្អីទេ មើលមិនយល់! សាណា ប្រហែលចូលចិត្តធ្វើរបស់បែបនេះ។



ម៉ារីប្រឹងលើករបស់ចតុកោណកែងនោះដាក់លើស្មា។
នាងជំពប់ជើងដួល។
នាងប្រឹងលើកម្តងទៀត លើកនេះងាយជាងមុន។



សំ បងប្រុសរបស់ម៉ារី សួរ ”ឯង អូសវាយកទៅណា?” ម៉ារី ឆ្លើយថា ”យកទៅរក សាណា”។





ម៉ារី ឃើញ សាណា នៅកន្លែងដែលនាងឧស្សាហ៍មកលេង។
ម៉ារី ប្រឹងឡើងលើដើមឈើទៅជិត សាណា។
តែ សាណា ជ្រួញចិញ្ចើមដាក់ ហើយនិយាយថា "ចេញទៅ!"



សំ ក៏ឡើងលើដើមឈើនោះដែរ ហើយទៅអង្គុយជិតម៉ារី។
សំ ហុចខ្សែឱ្យម៉ារី កាន់ ហើយ សំ កាន់ខ្សែខ្លួនឯងមួយដែរ។



សំ និងម៉ារី ដកដង្ហើមយ៉ាងវែង រួចបញ្ចេញកម្លាំងខំប្រឹងទាញ បន្ទះចតុកោណនោះឡើង។ គ្រឹកៗៗៗ! បន្ទាប់មក ពួកគេបាន ដាក់បន្ទះនោះផ្ដេក។





នៅពេលដែល ម៉ារី ឆ្លងទៅដល់ដើមឈើម្ខាងទៀត សាណា
នៅតែជ្រួញចិញ្ចើមដាក់ដដែល។ នាងបែរមុខចេញ សម្លឹង
មើលបន្ទះចតុកោណ ហើយងាកមកមើល ម៉ារីវិញ។
សាណា ចាប់ផ្ដើមញញឹម ហើយសួរថា "តើឯងគិតថា យើង
អាចធ្វើរទេះភ្លើងរត់លើវាបានទេ?"



ឆ្លងពីទីនេះ ទៅទីនោះ។ ម៉ារី ធ្វើស្ពានតូចមួយដើម្បីទៅជួប សាណា។ ប្រសិនបើស្ពានរបស់ពួកគេដាក់ភ្ជាប់ទៅលើដើមឈើ ទាំងសងខាង នោះវាក្លាយជាស្ពានឈើឆ្លង។ ស្ពានឈើឆ្លង ប្រភេទនេះងាយធ្វើជាងគេ។ ស្ពានឆ្លងអាចជាស្ពានធំ ធ្វើពីដែក និងស៊ីម៉ងត៍ ឬ អាចជាស្ពានតូច ធ្វើពីឈើ និងថ្ម។ តើអ្នកធ្លាប់ ឃើញស្ពានឆ្លងបែបនេះដែរឬទេ?

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org


**Original Story**
*The Grand Patch Up*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Hor Pheahong, Somey Chheang, chanmony kour, and Prum Kunthearo